ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សជណ-16/ 04-04-16/ផវ -បល-P.74

អគ្គិសនីកម្ពុជា

លេខ : ៣៦៩៧ សជណ.អក.បរ

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស **បុគ្គលិក** សម្រាប់ **ផ្នែកគំនូសប្លង់បច្ចេកទេស** និង **ផ្នែកបច្ចេកទេសសម្ភារ-បរិក្ខារអគ្គិសនី** សរុបចំនួន **០៧ រូប** ដើម្បីចូលបម្រើការងារ នៅការិយាល័យបច្ចេកទេសចែកចាយ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ AutoCAD, Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ការសិក្សា ឬ ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ មានបញ្ជាក់ពីអាជ្ញាធរដែនដី ចំនួន ០១ ច្បាប់
- តារាងពិន្ទុ ( TRANSCRIPT ) ចំនួន ០១ ច្បាប់

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រលងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦

ជ. **ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

**អេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។